ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
លេខ : ០៦៣១/២០ អ គ រ

ថ្ងៃចន្ទ ៩ កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបញ្ឈប់ការប្រើប្រាស់បង្កាន់ដៃពន្ធយានយន្តដែលសរសេរដោយដៃ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អគរ) នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា កន្លងមកនេះដោយសារប្រព័ន្ធស្វ័យប្រវត្តិកម្មគយ ពុំទាន់គ្របដណ្តប់ពេញលេញនៅទូទាំងប្រទេស មានការិយាល័យគយនិងរដ្ឋាករមួយចំនួន បានចេញបង្កាន់ដៃពន្ធយានយន្តសរសេរដោយដៃជូនធុរជន ហើយបង្កាន់ដៃទាំងនោះ អាចនៅពុំទាន់បានប្រើប្រាស់ក្នុងការចុះបញ្ជីធ្វើផ្លាកលេខនៅឡើយ ។

ក្នុងន័យខាងលើនេះ ផ្អែកតាមយន្តការនៃការតភ្ជាប់រវាងប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និងប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះនិងដើម្បីសម្រួលដល់នីតិវិធី នៃការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះរបស់ក្រសួងសាធារណការនិងដឹកជញ្ជូនបាន អគរ សូមជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា គ្រប់បង្កាន់ដៃពន្ធយានយន្តដែលបានសរសេរដោយដៃ មានចិរវេលាមិនលើសពី ១០(ដប់) ឆ្នាំ (ផ្អែកតាមច្បាប់ស្តីពីគយ) ត្រូវយកមកបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មគយឡើងវិញ នៅ អគរ (សាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ) រៀងរាល់ម៉ោងធ្វើការ ។

អគរ មិនទទួលខុសត្រូវរាល់ការខាតបង់នានា ដែលបណ្តាលមកពីការខកខានមិនបានអនុវត្តនូវយន្តការខាងលើនេះឡើយ។

អាស្រ័យហេតុនេះសូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

បណ្ឌិត គុណ ញឹម